# ឯកសារពិស្តារ

## ឧបករណ៍គណនេយ្យភាពសង្គម

# ការពិភាក្សាក្រុមជាក់លាក់



# ម៉ូឌុល៤: ឧបករណ៍គណនេយ្យភាពសង្គម

# មេរៀនៈ ការប្រជុំក្រុមជាក់លាក់

**មាតិកា** **ទំព័រ**

១-និយមន័យ ..... ៣
២-តើត្រូវអនុវត្តយ៉ាងដូចម្ដេច? ..... ៣
៣-ចំណុចខ្លាំង និងការប្រឈម ..... ៤

# ការពិភាក្សាក្រុមជាក់លាក់

១- និយមន័យ

ការពិភាក្សាក្រុមជាក់លាក់ ជាកិច្ចពិភាក្សាដែលមានការរៀបចំទុកជាមុន ប៉ុន្តែដំណើរការឬរចនាសម្ព័ន្ធអាចបត់បែនបាន ដោយមានអ្នកចូលរួមជាក់លាក់ (ដូចជា:ស្ត្រីងាយរងគ្រោះ យុវជន ចាស់ជរា និងកុមារកំព្រាគ្មានទីពឹង បងប្អូនខ្មែរអ៊ីស្លាមនិងជនជាតិដើមភាគតិច) មានចំនួនប្រមាណពី៦ទៅ១២នាក់។ ការពិភាក្សាដោយផ្ដោតលើក្រុមគោលដៅ មានរយៈពេលពី ១ទៅ២ម៉ោង និងផ្ដល់ឱកាសដល់សហគមន៍បង្ហាញ មតិយោបល់ បញ្ហាអាទិភាព និងតម្រូវការរបស់គាត់។

២- តើត្រូវអនុវត្តយ៉ាងដូចម្ដេច?

**២.១ ដំណាក់កាលរៀបចំ:**

លក្ខណៈវិនិច្ឆ័យសម្រាប់ជ្រើសរើសអ្នកចូលរួម ដែលមានភាពជាក់លាក់និងកំណត់ទុកជាមុន។ រាល់ប្រធានបទដែលនឹងត្រូវពិភាក្សាទាំងអស់មានការកំណត់ទុកជាមុន ហើយអ្នកសម្របសម្រួលប្រើបញ្ជីសំណួរបើក ដែលបានកំណត់ទុកតាមលំដាប់លំដោយនិងត។គ្នា។ អ្នកសម្របសម្រួលត្រូវចាំសំណួរជាមុនផងដែរ។

☞ **សមាសភាពក្រុម និង ការវិភាគទិន្នន័យដោយក្រុម**

សមាសភាពក្រុមពិភាក្សាដោយផ្ដោតលើក្រុមគោលដៅ គួរជាតំណាងនៃប្រជាជនគោលដៅ។ អ្នកចូលរួមគួរមានភាពប្រហាក់ប្រហែលគ្នា ដូចជា: ស្ថានភាពសង្គម អាយុ កម្រិតយល់ដឹង វប្បធម៌/ជាតិពិន្ទុ និងភេទ (និងអ្វីផ្សេងទៀតតាមការកំណត់របស់អ្នកសម្របសម្រួល)។ ការធ្វើដូច្នេះនឹងបង្កើតបរិយាកាសសមស្របដល់អ្នកចូលរួមមានអារម្មណ៍ស្និតស្នាលនិងហ៊ានបញ្ចេញយោបល់ដោយសេរី។

**២.២ ដំណាក់កាលអនុវត្ត**

ការពិភាក្សាក្រុមជាក់លាក ផ្អែកលើការពិភាក្សាក្នុងចំណោមអ្នកចូលរួមលើប្រធានបទដែលបានបង្ហាញ ហើយ សមាជិកក្រុមអាចបញ្ជាក់គ្នាទៅវិញទៅមក ដោយឆ្លើយតបនិងមានយោបល់បន្ថែមលើមតិយោបល់ ដែលបាន

លើកឡើងក្នុងពេលពិភាក្សា។ ទោះជាយ៉ាងនេះក្តី អ្នកសម្របសម្រួល ត្រូវសម្របសម្រួលឱ្យមានការឯកភាពគ្នាលើចំណុចរួមមួយ។

**២.៣ ការបូកសរុប និងធ្វើរបាយការណ៍**

**ទិន្នន័យគួរតែត្រូវបានវិភាគដោយក្រុម។** ការធ្វើដូច្នោះនឹងជួយឱ្យអាចធ្វើការប្រៀបធៀបលទ្ធផលរបស់ក្រុមផ្សេងៗគ្នាបាន។

៣- ចំណុចខ្លាំង និងការប្រឈម

ចំណុចខ្លាំង

គុណសម្បត្តិនៃការពិភាក្សាក្រុមជាក់លាកល្អជាងការសម្ភាសន៏ម្នាក់ម្តងៗ ដោយយោបល់របស់អ្នកចូលរួមម្នាក់អាចបំផុសអ្នកចូលរួមដទៃទៀតឱ្យមានយោបល់។ យោបល់និងគំនិតសម្បូរបែបជាងការសម្ភាសន៍ម្នាក់ម្តងៗ។ អ្នកស្រាវជ្រាវនិងអ្នកសម្ភាសន៍អាចទទួលបានគំនិតដែលកើតចេញពីការពិភាក្សាទាំនេះ។ ក្នុងរយៈពេលខ្លីបរិមាណព័ត៌មានដ៏ច្រើនត្រូវបានប្រមូល-ជាទូទៅឆាប់រហ័សជាងនិងចំណាយតិចជាងការសម្ភាសន៏ម្នាក់ម្តងៗ។

ការពិភាក្សាក្រុមជាក់លាកមានសារៈសំខាន់សម្រាប់ការទទួលព័ត៌មាន អំពីជំនឿ គំនិត ទស្សនៈ ឥរិយាបថ និង អត្តចរិតក្នុងសហគមន៍។ ការពិភាក្សាក្រុមជាក់លាកពិតជាមានប្រយោជន៏ សម្រាប់កំណត់សំណួរសមហេតុផល និងត្រឹមត្រូវសម្រាប់ការសម្ភាសន៏ម្នាក់ម្តងៗ (ផ្លូវការ ឬ មិនផ្លូវការ)។

ការប្រឈម

- អ្នកស្រាវជ្រាវអាចគ្រប់គ្រងលំហូរនៃការពិភាក្សាក្រុមជាក់លាកបានតិចតួចជាងការសម្ភាសន៍ម្នាក់ម្តងៗ។
- ការពិភាក្សាក្រុមជាក់លាកមិនអាចគណនា ឬបូកសរុប ជាបរិមាណ ឬ មធ្យមភាគបាននោះទេ។
- លទ្ធផលពិបាកការវិភាគជាងការសម្ភាសន៍ម្នាក់ម្តងៗ។ យោបល់របស់អ្នកចូលរួមត្រូវតែបកស្រាយក្នុងបរិបទសង្គមមួយដែលបង្កើតដោយការពិភាក្សា ដោយផ្តោតលើក្រុមគោលដៅ (ការពិភាក្សាក្នុងចំណោមមនុស្សចម្លែកនៅទីណាមួយ) ហើយត្រូវប្រុងប្រយ័ត្នដើម្បីជៀសវាងការលើកយោបល់ខុសពីបរិបទ ឬ ហេតុផល)។
- ដោយសារពេលវេលា ចំនួនសំណួរដែលត្រូវបានសួរមានចំនួនតិច ជាងការសម្ភាសន៏ម្នាក់ម្តងៗ

- ការសម្របសម្រួលនិងរៀបចំការពិភាក្សាក្រុមជាក់លាក់ទាមទារឱ្យមានជំនាញច្បាស់លាស់។ ការដឹងពីរបៀបគ្រប់គ្រងការសម្ភាសន៍ដើម្បីបញ្ជៀសនរណាម្នាក់មិនឱ្យគ្របសង្កត់លើក្រុមពិតជាសំខាន់ខ្លាំងណាស់ ហើយអ្នកចូលរួមអាចចែករំលែកទស្សនៈរបស់ពួកគេ។
- ពេលការពិភាក្សាបានបញ្ចប់ ការវិភាគព័ត៌មានត្រូវការរយៈពេលវែងនិងចំណាយច្រើន។ ជាទូទៅអ្នកស្រាវជ្រាវត្រូវស្តាប់សំឡេងពីការពិភាក្សាក្រុមជាក់លាក់ដែលបានថតឡើងវិញ បកស្រាយយោបល់ដាក់លេខកូដ និងវិភាគយោបល់ទាំងនោះ ។ល។ ជំហានទាំងអស់នេះ ត្រូវការរយៈពេលយូរនិងត្រូវការជំនាញច្បាស់លាស់។